**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១១៧ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការគ្រប់គ្រងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤០៦/១៨៣ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៦០៦/២៤៨ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិ ដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ
- បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៣ ខែតុលា ឆ្នាំ ២០០៦

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ និងគ្រប់គ្រងតំបន់រមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ។

**មាត្រា ២ .-**

អនុក្រឹត្យនេះ មានគោលបំណងដូចតទៅ ÷

- ធានាការអភិវឌ្ឍតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារប្រកបដោយចីរភាព និងបរិស្ថាន
- អភិរក្សកេរដំណែលវប្បធម៌ និងធនធានធម្មជាតិ
- ជំរុញការទាក់ទាញទេសចរជាតិ និងអន្តរជាតិ ។

**មាត្រា ៣ .-**

អនុក្រឹត្យនេះ មានវិសាលភាពលើរាល់តំបន់ការពារតាមប្លង់កំណត់ ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/ ០៤០៦/១៨៣ ចុះ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ ។

**មាត្រា ៤ .-**

ការរៀបចំ ចាត់ចែង និងគ្រប់គ្រងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ជាសមត្ថកិច្ចរបស់អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ដែលបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/ រកត/ ០៦០៦/២៤៨ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦ ដោយមានកិច្ចសហការជិតស្និទ្ធ និងជាប្រចាំជាមួយអាជ្ញាធរដែនដី ។/

# ជំពូកទី ២

# ការគ្រប់គ្រង និង ការអភិវឌ្ឍ

## ផ្នែកទី ១

## ការអភិវឌ្ឍតំបន់ប្រាសាទព្រះវិហារ

**មាត្រា ៥ .-**

ក្នុងរាល់កិច្ចអភិវឌ្ឍន៍រមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ទាំង ៤ (បួន) អ.ជ.ព.វ ត្រូវ ÷

- រៀបចំនីតិក្រម សម្រាប់ពិនិត្យឡើងវិញ និងអនុម័តគម្រោងអភិវឌ្ឍន៍នៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ
- ធានាថា រាល់គម្រោងអភិវឌ្ឍន៍ ត្រូវបានគិតគូរអំពីផលប៉ះពាល់បរិស្ថាន មានគម្រោងសម្រាប់ជំនួស និងបន្ថយផលប៉ះពាល់អវិជ្ជមានឱ្យមានកម្រិតទាបបំផុត
- បញ្ចូលការវាយតម្លៃ ផលប៉ះពាល់បរិស្ថាន ក្នុងការស្រាវជ្រាវវត្ថុបុរាណ នៅតំបន់ពាក់ព័ន្ធទាំងនោះ
- ធ្វើកំណាយសង្គ្រោះផ្នែកបុរាណវិទ្យា ដើម្បីប្រមូលទិន្នន័យផ្នែកបុរាណវិទ្យា និងវត្ថុបុរាណមករក្សាទុកជាមុនសិន បើជាការចាំបាច់ មុននិងចាប់ផ្តើមដំណើរការអភិវឌ្ឍ។

**មាត្រា ៦ .-**

ការអភិវឌ្ឍក្នុងរមណីយដ្ឋានមានប្រាសាទក្នុងតំបន់ ១ ត្រូវហាមឃាត់ លើកលែងតែការអភិវឌ្ឍណា ដែលមានសារប្រយោជន៍សម្រាប់កិច្ចការពារ និងការលើកស្ទួយតម្លៃនៃរមណីយដ្ឋាននោះ ។

ការអភិវឌ្ឍក្នុងរមណីយដ្ឋានមានប្រាសាទក្នុងតំបន់ ២ ត្រូវហាមឃាត់ លើកលែងតែការអភិវឌ្ឍណា ដែលមានសារប្រយោជន៍ សម្រាប់កិច្ចការពារ និងការលើកស្ទួយតម្លៃនៃស្ថានីយបុរាណវត្ថុនោះ ។

**មាត្រា ៧ .-**

រាល់កិច្ចអភិវឌ្ឍន៍រមណីយដ្ឋានវប្បធម៌ធម្មជាតិក្នុងតំបន់ ៣ អ.ជ.ព.វ ត្រូវកំណត់ប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី ដែលត្រូវបានទទួលការយល់ព្រមពីរាជរដ្ឋាភិបាល។

រាល់ការអភិវឌ្ឍនៅតាមបណ្តោយព្រំដែន ត្រូវមានការឯកភាពពីគណៈកម្មាធិការចម្រុះកិច្ចការព្រំដែននៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

រាល់ការផ្តល់លិខិតអនុញ្ញាតសាងសង់ ត្រូវចេញដោយ អ.ជ.ព.វ ហើយត្រូវគោរពតាម បទប្បញ្ញត្តិនគរូបនីយកម្ម និងសំណង់ ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

រាល់ការចេញប័ណ្ណកម្មសិទ្ធដីធ្លី ស្ថាប័នមានសមត្ថកិច្ចត្រូវមានការឯកភាពពី អ.ជ.ព.វ.។

**មាត្រា ៨ .-**

រាល់ការអភិវឌ្ឍសំណង់នានាក្នុងតំបន់ ៣ អ.ជ.ព.វ ត្រូវគិតគូរអំពីគុណភាពល្អប្រណិត រចនាប័ទ្មខ្មែរ គួបផ្សំនឹង សម័យទំនើប ដោយលើកទឹកចិត្តការប្រើប្រាស់ជាបឋម នូវសម្ភារៈសំណង់ដែលមាន ក្នុងស្រុក ហើយកម្ពស់សំណង់កម្រិតមិនឱ្យលើសពី ១០ ម៉ែត្រ (ដប់ម៉ែត្រ) គិតពីផ្ទៃដីកម្ពស់សូន្យម៉ែត្រ ដល់ស្នាបជញ្ជាំង ។

## ផ្នែកទី ២

## អំពីបុរាណវត្ថុវិទ្យា

**មាត្រា ៩ .-**

ក្នុងសកម្មភាពបុរាណវិទ្យា នៅរមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ទាំង ៤ អ.ជ.ព.វ ត្រូវ ÷

- រៀបចំកម្មវិធីលំអិត ដើម្បីសម្រង់ព័ត៌មានបុរាណវត្ថុ នៅតំបន់ប្រាសាទព្រះវិហារ
- ធ្វើបញ្ជីសារពើភ័ណ្ឌស្ថានីយបុរាណវត្ថុនៅតំបន់ប្រាសាទព្រះវិហារ ហើយបញ្ចូលបញ្ជីនោះទៅក្នុងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ
- កំណត់លក្ខណៈវិនិច្ឆ័យ ព្រមទាំងកម្មវិធីសម្រាប់សំគាល់ស្ថានីយណាដែលជាចំណុចមានផលប្រយោជន៍ ផ្នែកបុរាណវិទ្យា នរវិទ្យា ឬ ប្រវត្តិវិទ្យា
- រៀបចំទិសដៅ និងគំរូកិច្ចព្រមព្រៀងសម្រាប់ចាត់ចែង គ្រប់គ្រងស្ថានីយទាំងអស់នោះ ក្នុងគោលបំណងស្រាវជ្រាវផ្នែកបុរាណវិទ្យា អប់រំ ឬ ទស្សនា
- កំណត់លក្ខណៈវិនិច្ឆ័យព្រមទាំងកម្មវិធី សម្រាប់សំគាល់ទេសភាពវប្បធម៌ត្រូវការពារ
- កំណត់ទិសដៅនយោបាយ ដើម្បីចាត់ចែងគ្រប់គ្រងទេសភាពវប្បធម៌ទាំងអស់នោះ ក្នុងគោលបំណងស្រាវជ្រាវផ្នែកបុរាណវិទ្យា អប់រំ ឬ ទស្សនា
- ដាក់ឱ្យមានអ្នកយាមល្បាត ដើម្បីថែទាំ និងការពារស្ថានីយនីមួយៗ ។

**មាត្រា ១០ .-**

អ.ជ.ព.វ ត្រូវការពារយ៉ាងមធ្យ័តបរិវេណរមណីយដ្ឋានមានប្រាសាទក្នុងតំបន់ ១ ហើយគ្រប់គ្រងបរិវេណទាំងនោះ ក្នុងគោលបំណងស្រាវជ្រាវផ្នែកបុរាណវិទ្យា អប់រំ ឬ ទស្សនា ។

**មាត្រា ១១ .-**

អ.ជ.ព.វ ត្រូវ ÷

- ការពារយ៉ាងមធ្យ័តស្ថានីយបុរាណវត្ថុទាំងអស់ ព្រមទាំងសំណល់វប្បធម៌ដែលស្ថិតនៅលើដី ឬ ក្រោមដីក្នុងតំបន់ ២

- ត្រួតពិនិត្យ និងគ្រប់គ្រងរាល់សកម្មភាពនានា ដែលអាចបណ្តាលឱ្យមានផលប៉ះពាល់ អវិជ្ជមានដល់ស្ថានីយបុរាណវត្ថុទាំងអស់នោះ ។

## ផ្នែកទី ៣
## ការចាត់ចែងគ្រប់គ្រងទស្សនិកជន

**មាត្រា ១២ ..**

ក្នុងការចាត់ចែងគ្រប់គ្រងទស្សនិកជននៅរមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ទាំង ៤ អ.ជ.ព.វ ត្រូវ ÷

- គ្រប់គ្រងការចេញ ចូលរបស់សាធារណជន ដែលមានគោលបំណងស្រាវជ្រាវផ្នែកបុរាណវិទ្យាក្តី អប់រំក្តី និងទស្សនាក្តី

- អនុវត្តតាមគម្រោង និងទិសដៅច្បាស់លាស់ដោយកម្រិតទាំងពេលវេលាចេញ ចូលទាំងតម្លៃប័ណ្ណទស្សនា ទាំងតម្លៃកំសាន្តផ្សេងៗទៀត ចំពោះរាល់ការចេញ ចូលរបស់ទស្សនិកជន

- ទប់ស្កាត់រាល់សកម្មភាពបង្កការប៉ះពាល់គុណភាពបរិស្ថាន បណ្តាលមកពីទស្សនិកជន និងសាធារណជន ។

**មាត្រា ១៣ ..**

ក្នុងការគ្រប់គ្រងទស្សនិកជនក្នុងតំបន់ ១ អ.ជ.ព.វ ត្រូវ ÷

- កំណត់ និងរៀបចំការចេញ ចូលទស្សនាតាមបែបបទ

- ដាក់ឱ្យមានជាប្រចាំនូវមន្ត្រីរបស់អាជ្ញាធរជាតិ ដើម្បីផ្តល់ព័ត៌មានណែនាំ ថែរក្សាសន្តិសុខ គុណភាពបរិស្ថាន និងផ្តល់សេវាផ្សេងៗដល់ទស្សនិកជន

- កំណត់តម្លៃប័ណ្ណទស្សនា ដោយមានការពិភាក្សា ឯកភាពជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីប្រមូលចំណូល យកមកថែរក្សា និងចាត់ចែងគ្រប់គ្រងរមណីយដ្ឋាននោះ

- កម្រិតចំនួន និងទំហំក្រុមទស្សនិកជន ដើម្បីរក្សាគុណភាពទស្សនកិច្ច និងដើម្បីងាយស្រួលការពារប្រាង្គប្រាសាទ

- ត្រួតពិនិត្យយ៉ាងហ្មត់ចត់នូវប្រភេទរថយន្តដែលអនុញ្ញាតឱ្យចេញ ចូល កម្រិតល្បឿនបើកបរ កំណត់ពេលវេលាឡើងចុះ និងតម្រូវឱ្យចូលចតនៅទីលានចំណតដែលបានកំណត់ ។

**មាត្រា ១៤ ..**

ក្នុងការគ្រប់គ្រងទស្សនិកជនក្នុងតំបន់ ២ អ.ជ.ព.វ ត្រូវ ÷

- ហាមឃាត់រថយន្តដឹកជញ្ជូនធុនធ្ងន់ឆ្លងកាត់ ដែលគ្មានការអនុញ្ញាតពីអាជ្ញាធរជាតិ លើកលែងតែកំណាត់ផ្លូវចាប់ពីច្រកចេញ ចូលតាជាវ និងផ្លូវតាមរង្វង់ព័ទ្ធជុំវិញតំបន់ ២

- កែលំអផ្លូវចេញ ចូល សម្រាប់អ្នករស់នៅក្នុងតំបន់នោះ ដោយជៀសវាងការប៉ះពាល់រមណីយដ្ឋានប្រាសាទបុរាណ

- កំណត់ទីតាំងទទួលភ្ញៀវ ទស្សនិកជន និងទីលានចំណតនៅក្នុងតំបន់ទ្រនាប់

- បង្កើតឱ្យមានផ្លូវថ្មីៗ វង់ព័ទ្ធជុំវិញរមណីយដ្ឋានប្រាសាទព្រះវិហារ និងបង្វែរផ្លូវទាំងឡាយដែលបណ្តាល ឱ្យប៉ះពាល់ដល់តំបន់ការពាររមណីយដ្ឋានប្រាសាទ

- រក្សា និងទុកប្រើប្រាស់កំណាត់ផ្លូវចាប់ពីចំណុច F ទៅចំណុច T សម្រាប់ជាសេវាទេសចរណ៍ធ្វើដំណើរដោយថ្មើរជើង ជិះសេះ ជិះដំរី ឬទោចក្រយានយន្ត បន្ទាប់ពីចំណតរថយន្តត្រូវបានរៀបចំហើយ និងផ្លូវបុរាណ GB ឬផ្លូវមួយផ្សេងទៀត ត្រូវបានស្តារ និងដាក់ឱ្យដំណើរការជាមុនសិន ។

## ជំពូកទី ៤
## សំណង់ទេសចរណ៍

**មាត្រា ១៥ ._**

គ្រប់ការសាងសង់សំណង់ទេសចរណ៍នៅក្នុងរមណីយដ្ឋានវប្បធម៌ ក្នុងតំបន់ទាំង ៤ ត្រូវមានការអនុញ្ញាតពី អ.ជ.ព.វ និងប្រព្រឹត្តទៅតាមបទបញ្ជារបស់ អ.ជ.ព.វ ។

អ.ជ.ព.វ ត្រូវបង្កើតឱ្យមានមធ្យោបាយដឹកភ្ញៀវទេសចរឡើងចុះភ្នំប្រាសាទព្រះវិហារ ។ ទន្ទឹមនេះ អ.ជ.ព.វ ត្រូវបង្កលក្ខណៈ សម្បត្តិដល់ប្រជាពលរដ្ឋ ដែលមានបំណងចូលរួមក្នុងការដឹកជញ្ជូន ភ្ញៀវទេសចរផងដែរ ។

**មាត្រា ១៦ ._**

រាល់សំណង់ទេសចរណ៍ ក្នុងតំបន់ ១ អ.ជ.ព.វ ត្រូវ ÷

- អនុញ្ញាតឱ្យមានសំណង់តិចបំផុត ហើយជាសំណង់ស្រាលនិងលាក់ក្នុងព្រៃសម្រាប់ទស្សនិកជន

- កំណត់ទីកន្លែង និងរៀបចំឱ្យមានទីលានចំណតទោចក្រយានយន្ត រថយន្តទេសចរណ៍ធុនតូចឱ្យតិចបំផុត

- រៀបចំកន្លែងឱ្យទស្សនិកជនបានទស្សនាកំណាយខាងបុរាណវិទ្យា និងការងារជួសជុលប្រាសាទដែលនឹងត្រូវអនុវត្ត

-រៀបចំ ជួសជុល កែលំអជណ្តើរបុរាណក្នុងតំបន់ ២ ដោយរក្សាទុកចំណីដីចម្ងាយ ៥០ (ហាសិប) ម៉ែត្រសងខាង ចាប់ពីអ័ក្សជណ្តើរ ដើម្បីបើកឱ្យទេសចរប្រើប្រាស់ ។

**មាត្រា ១៧ .-**

រាល់សំណង់ទេសចរណ៍ក្នុងតំបន់ ២ អ.ជ.ព.វ ត្រូវកំណត់ទីកន្លែង និងរៀបចំឱ្យមានទីលានចំណតទោចក្រយានយន្ត រថយន្តទេសចរណ៍ធុនតូច ធំ និងមីនីប៊ីស ។

**មាត្រា ១៨ .-**

ក្នុងតំបន់ ៣ អ.ជ.ព.វ ត្រូវ ÷

- បន្ថយហេតុផលប៉ះពាល់អវិជ្ជមានបណ្តាលមកពីទេសចរណ៍ទៅលើសហគមន៍រស់នៅទីនោះ
- រៀបចំទីកន្លែងតូចៗ និងមជ្ឈមណ្ឌលសិប្បកម្ម ដើម្បីផ្តល់លទ្ធភាពផ្នែកសេដ្ឋកិច្ចដល់អ្នករស់នៅទីនោះ ។

## ផ្នែកទី ៥

## ការបង្ហាញរមណីយដ្ឋានវប្បធម៌

**មាត្រា ១៩ .-**

ក្នុងការបង្ហាញរមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ទាំង ៤ អ.ជ.ព.វ ត្រូវ ÷

- រៀបចំផែនការ ដើម្បីបង្ហាញបុរាណវិទ្យា នរវិទ្យា ព្រមទាំងតំបន់ការពារធម្មជាតិ និងប្រពៃណីអ្នកស្រុកនៃតំបន់
- បង្កើតមជ្ឈមណ្ឌលព័ត៌មាននៅក្រៅរមណីយដ្ឋានត្រូវការពារដាច់ខាត ដើម្បីផ្តល់ជូនទស្សនិកជននូវការណែនាំស្តីពីបេតិកភណ្ឌប្រាសាទព្រះវិហារ ។

**មាត្រា ២០ .-**

ក្នុងតំបន់ ១ និងតំបន់ ២ អ.ជ.ព.វ ត្រូវរៀបចំដំណើរទស្សនកិច្ច ឱ្យមានមគ្គុទ្ទេសក៍ និងដាក់ផ្លាកសញ្ញាបង្ហាញពីរមណីយដ្ឋានដែលមានលក្ខណៈដោយឡែក ដូចជា ពើងតាឌី ការដ្ឋានយកថ្មកសាង ប្រាសាទ និងស្រះបុរាណ ។

**មាត្រា ២១ .-**

ក្នុងតំបន់ ៣ អ.ជ.ព.វ ត្រូវបង្ហាញពីជីវភាពរស់នៅរបស់ប្រជាជនដូចជា ទស្សនីយភាពផ្នែករបាំបុរាណ ប្រពៃណី ទំនៀមទម្លាប់ ផលិតកម្មសិប្បកម្ម និងទិដ្ឋភាពពិសេសៗពាក់ព័ន្ធដល់ទីតាំង ពេលវេលាដោយឡែករបស់ភ្នំប្រាសាទព្រះវិហារ ។

## ផ្នែកទី ៦
## ការដ្ឋានយកថ្ម

**មាត្រា ២២ .-**

ការធ្វើអាជីវកម្មយកថ្មនៅរមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ទាំង ៤ អ.ជ.ព.រ ត្រូវ ÷

- កំណត់ និងការពារការដ្ឋានជីកយកថ្មបាយក្រៀម និងថ្មភក់នៅក្នុងរមណីយដ្ឋានដែលត្រូវការពារ សម្រាប់យកមកប្រើប្រាស់ក្នុងការជួសជុលបុរាណវត្ថុ និងប្រាង្គប្រាសាទ ក្រោយពីបានធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងបានការអនុញ្ញាតពី អ.ជ.ព.រ រួច

- ហាមឃាត់ការជីកកកាយយកដីឥដ្ឋ និងថ្មក្នុងរមណីយដ្ឋាននានាដែលត្រូវការពារ ដើម្បីយកទៅប្រើប្រាស់ក្នុងការស្ថាបនាផ្លូវ ឬសំណង់ផ្សេងៗទៀត ។

## ផ្នែកទី ៧
## ការចាត់ចែងទឹក

**មាត្រា ២៣ .-**

ក្នុងការចាត់ចែងទឹកនៅរមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ការពារទាំង ៤ អ.ជ.រ.ព ត្រូវ ÷

- ជួសជុលដោយផ្នែកៗនូវរចនាសម្ព័ន្ធធារាសាស្ត្របុរាណ និងចាត់ចែងរបបគ្រប់គ្រងទឹក តាមសំណង់ ធារាសាស្ត្រថ្មី និងមានប្រសិទ្ធភាព

- ជៀសវាងការប្រើបច្ចេកវិទ្យា និងរចនាសម្ព័ន្ធថ្មី ដែលអាចធ្វើឱ្យប៉ះពាល់ដល់សំណង់បុរាណ ។

**មាត្រា ២៤ .-**

ក្នុងតំបន់១ អ.ជ.ព.រ ត្រូវថែរក្សាស្រះបុរាណ អូរធម្មជាតិដែលមានស្រាប់ និងការពារនូវបរិស្ថាន ។

**មាត្រា ២៥ .-**

ក្នុងតំបន់ ២ អ.ជ.ព.រ ត្រូវ ÷

- ថែរក្សាស្រះ អាងស្តុកទឹក និងអូរធម្មជាតិ ដែលមានស្រាប់ និងការពារនូវបរិស្ថាន

- ថែរក្សា នឹងពង្រីងអាងស្តុកទឹកដែលមានស្រាប់ ដោយបង្កើនគុណភាពទឹកឱ្យបានស្អាត និងមានបរិស្ថានល្អ ។

**មាត្រា ២៦ .-**

ក្នុងតំបន់ ៣ អ.ជ.ព.រ ត្រូវអភិវឌ្ឍធារាសាស្ត្រតូចៗ ដើម្បីបង្កើនផលិតផលកសិកម្ម និងដើម្បីការប្រើប្រាស់ផ្ទាល់របស់អ្នករស់នៅទីនោះ ដោយមិនធ្វើឱ្យប៉ះពាល់ដល់បុរាណវត្ថុ ។

## ផ្នែកទី ៨
## ការចាត់ចែងគ្រប់គ្រងទេសភាព

**មាត្រា ២៧ .-**

ក្នុងការចាត់ចែងគ្រប់គ្រងទេសភាពនៅរមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ទាំងអស់ អ.ជ.ព.រ ត្រូវ ៖

- ការពារ និងបង្កើនតម្លៃទេសភាពវប្បធម៌គ្រប់ការអភិវឌ្ឍ
- បញ្ចូលទៅក្នុងផែនការ និងសកម្មភាពនៃការចាត់ចែងគ្រប់គ្រងរមណីយដ្ឋាន រាល់គោលនយោបាយ និងទិសដៅសម្រាប់ការចាត់ចែងគ្រប់គ្រងទេសភាព ។

**មាត្រា ២៨ .-**

ក្នុងតំបន់ ១ អ.ជ.ព.រ ត្រូវ ៖

- រៀបចំបង្ហាញសភាពដើមពិតនៃបុរាណវិទ្យា ដោយរៀបចំទេសភាពឱ្យមានលក្ខណៈសមស្របតាមបុរាណវិទ្យា
- ចាត់ចែងរៀបចំទេសភាពនៅជុំវិញប្រាសាទ ។

**មាត្រា ២៩ .-**

ក្នុងតំបន់ ២ អ.ជ.ព.រ ត្រូវរក្សា និងបង្កើតព្រៃទ្រនាប់ ។

**មាត្រា ៣០ .-**

ក្នុងតំបន់ ៣ អ.ជ.ព.រ ត្រូវលើកស្ទួយតម្លៃទេសភាព តាមរយៈការបង្កើតសកម្មភាពកសិកម្ម និងការរៀបចំដែនដី ។

## ផ្នែកទី ៩
## ការចាត់ចែងគ្រប់គ្រងធនធានធម្មជាតិ

**មាត្រា ៣១ .-**

រាល់ការចាត់ចែងគ្រប់គ្រងធនធានធម្មជាតិនៅរមណីយដ្ឋានវប្បធម៌ធម្មជាតិ ក្នុងតំបន់ ១, ២ និង ៣ អ.ជ.ព.រ ត្រូវគ្រប់គ្រងទឹក ព្រៃឈើ និងសត្វព្រៃ ដើម្បីថែរក្សានិងបង្កើនជីវចម្រុះ ។

រាល់ការចាត់ចែង និងគ្រប់គ្រងធនធានធម្មជាតិនៅតំបន់ ៤ ត្រូវអនុលោមតាមបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា ៣២ .-**

ក្នុងតំបន់ ១ អ.ជ.ព.វ ត្រូវ ÷

- ថែរក្សា និងដាំឡើងវិញ នូវព្រៃឈើធម្មជាតិ ទឹក និង ដីព្រៃឈើ

- ថែទាំ ដាំដើមឈើនៅជុំវិញប្រាសាទឱ្យបានគង់វង្ស ។ យកចេញដើមឈើដែលប៉ះពាល់ដល់សោភ័ណភាព ឬអាចបំផ្លាញដល់ប្រាង្គប្រាសាទ ។

**មាត្រា ៣៣ .-**

ក្នុងតំបន់ ២ និងតំបន់ ៣ អ.ជ.ព.វ ត្រូវ ÷

- បង្កើនសួនរុក្ខជាតិ និងផ្លូវលំតាមដងព្រៃ
- ចាប់ផ្តើមអនុវត្តកម្មវិធីដាំដើមឈើ ដែលមានពូជនៅក្នុងតំបន់នេះ ។

## ផ្នែកទី ១០
## អំពីអ្នករស់នៅតាមតំបន់

**មាត្រា ៣៤ .-**

ក្នុងរមណីយដ្ឋានវប្បធម៌ធម្មជាតិ តំបន់ទាំង ៤ អ.ជ.ព.វ ត្រូវផ្តល់អាទិភាពការងារដល់អ្នករស់នៅក្នុងរមណីយដ្ឋានត្រូវការពារក្នុងវិស័យចាត់ចែងគ្រប់គ្រងថែទាំរមណីយដ្ឋាន ។

**មាត្រា ៣៥ .-**

ក្នុងតំបន់ ១ និងតំបន់ ២ អ.ជ.ព.វ មិនអនុញ្ញាតឱ្យមានភូមិ និងទីប្រជុំជន ។

**មាត្រា ៣៦ .-**

ក្នុងតំបន់ ៣ និងតំបន់ ៤ អ.ជ.ព.វ ត្រូវ ÷

- បង្កលក្ខណៈងាយស្រួល ជួយជំរុញ និងឧបត្ថម្ភដល់ប្រជាពលរដ្ឋរស់នៅឱ្យបង្កបង្កើនផលកសិកម្មស្រូវ និងដំណាំផ្លែឈើហូបផ្លែ និងដាំបន្លែបង្ការសម្រាប់បម្រើឱ្យភ្ញៀវទេសចរ ដើម្បីបន្ថយការនាំចូលពីបរទេស និងបង្កើនការងារជូនប្រជាពលរដ្ឋ

- រក្សាទុកការប្រើប្រាស់តាមប្រពៃណីនូវដីស្រែ និងវាលស្មៅសម្រាប់សត្វ ។

## ផ្នែកទី ១១
## អំពីវត្តអារាម

**មាត្រា ៣៧ ..**

ក្នុងតំបន់ ១ និងតំបន់ ២ អ.ជ.ព.វ មិនអនុញ្ញាតឱ្យមានវត្ត ឬទីតាំងសាសនាផ្សេងៗ ទេ ។

**មាត្រា ៣៨ ..**

ក្នុងតំបន់ ៣ និងតំបន់ ៤ ការបង្កើតវត្តថ្មីនៅតាមភូមិនានាត្រូវគោរពតាមបទប្បញ្ញត្តិច្បាប់ ។

**មាត្រា ៣៩..**

មិនអនុញ្ញាតឱ្យស្នាក់អាស្រ័យពេលយប់នៅក្នុងប្រាង្គប្រាសាទព្រះវិហារ ។

## ផ្នែកទី ១២
## អំពីសិប្បកម្ម និង សេវាកម្ម

**មាត្រា ៤០ ..**

មិនអនុញ្ញាតឱ្យមានការអភិវឌ្ឍឧស្សាហកម្ម ឬពាណិជ្ជកម្មក្នុងរមណីយដ្ឋានការពារ នៅតំបន់ ១ តំបន់ ២ និងតំបន់ ៣ លើកលែងតែសិប្បកម្ម ឬ សេវាកម្មមានទ្រង់ទ្រាយតូចៗបម្រើឱ្យវិស័យទេសចរណ៍ ចាំបាច់ក្នុងការថែទាំ និងកិច្ចការពារទេសភាព វប្បធម៌ និងតំបន់បម្រុងផ្នែកបុរាណវិទ្យា ។

ត្រូវគ្រប់គ្រងឱ្យបានត្រឹមត្រូវរាល់សំណង់បង្កើតឡើងដោយសិប្បកម្ម និងសេវាកម្ម ។

**មាត្រា ៤១ ..**

ក្នុងតំបន់ ១ និងតំបន់ ២ អ.ជ.ព.វ ត្រូវកំណត់ទីតាំង ទំហំ និងចំនួនលក់ដូរវត្ថុទាំងឡាយបម្រើឱ្យទេសចរណ៍ឱ្យតិចបំផុត ។

**មាត្រា ៤២ ..**

ក្នុងតំបន់ ៣ អ.ជ.ព.វ ត្រូវ ÷

- បង្កើត និងបង្កើនរោងសិប្បកម្មនៅក្នុងភូមិដែលមានស្រាប់ ឬក្នុងមជ្ឈមណ្ឌលទទួលទេសចរ
- ជំរុញសិប្បកម្មតូចៗ និងក្នុងការផលិតវត្ថុអនុស្សាវរីយ៍ ។

## ផ្នែកទី ១៣
## អំពីបណ្តាញចរន្តអគ្គិសនី

**មាត្រា ៤៣ .-**

ក្នុងតំបន់ ១ តំបន់ ២ និងតំបន់ ៣ អ.ជ.ព.វ ÷

- ត្រូវបានអនុញ្ញាតឱ្យដាក់បណ្តាញចរន្តអគ្គិសនី ដែលផ្តល់អគ្គិសនីដល់មូលដ្ឋាននោះ ដោយរក្សាសោភ័ណភាពធម្មជាតិ
- គ្រប់គ្រងរាល់ការតុបតែង និងការរៀបចំពិធីផ្សេងៗក្នុងតំបន់ ដែលត្រូវអនុវត្តតាមលក្ខណៈបច្ចេកទេស ។

## ផ្នែកទី ១៤
## ការទាក់ទាញអារម្មណ៍ចំពោះបរិស្ថាន

**មាត្រា ៤៤ .-**

ក្នុងតំបន់ទាំង ៤ អ.ជ.ព.វ ត្រូវផ្តើមអនុវត្តកម្មវិធី ដើម្បីឱ្យមានការទាក់ទាញអារម្មណ៍ប្រជាជនមូលដ្ឋាន និងទស្សនិកជន ចំពោះសារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌ ធម្មជាតិ និងចំពោះបញ្ហា បរិស្ថាន ។

**មាត្រា ៤៥ .-**

ក្នុងតំបន់ ១ អ.ជ.ព.វ ត្រូវ ÷

- កំណត់ទីតាំង និងរៀបចំតូបលក់ដូរវត្ថុអនុស្សាវរីយ៍តាមរចនាប័ទ្មខ្មែរ
- កំណត់ទីតាំង និងរៀបចំឱ្យមានបង្គន់អនាម័យ ធុងដាក់សំរាមឱ្យបានត្រឹមត្រូវ តាមលក្ខណៈបច្ចេកទេស ។

## ផ្នែកទី ១៥
## ការបណ្តុះបណ្តាលធនធានមនុស្ស

**មាត្រា ៤៦ .-**

អ.ជ.ព.វ ត្រូវ ÷

- បណ្តុះបណ្តាលកម្មករសម្រាប់ការដ្ឋានកំណាយ និងការជួសជុល
- បណ្តុះបណ្តាលមគ្គុទ្ទេសក៍ ឆ្មាំឧទ្យាន និងបុគ្គលិកថែទាំ
- បណ្តុះបណ្តាលបុរាណវិទូ ស្ថាបត្យករជួសជុល និងអ្នកប្រកបវិជ្ជាជីវៈផ្សេងៗទៀត ក្នុងផ្នែកចាត់ចែងគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ធម្មជាតិ

- យកចិត្តទុកដាក់ដល់ប្រជាពលរដ្ឋក្នុងតំបន់មុនគេ ដើម្បីរក្សានិរន្តរភាព ក្នុងការការពារ និងការអភិវឌ្ឍ បានយូរអង្វែង ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**មាត្រា ៤៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ